# *រឿង មហាចោរនៅទល់ដែន*

***ភាគទី៦៥*** *(ក្បួនការពារឯកពជ្យ)*

*មហាកាលសើច:*

*ឯងសងសឹកឲ្យអញតទៅទៀត។*

*អារុណងក់ក្បាល:*

*ប្រាកដហើយ! កុំយូរពេក! ទៅសង្គ្រាម! ជយោសង្គ្រាម*

*វីរៈចង់ចិញ្ចើមគំហ៊កថា:*

*ជយោសន្តិភាព! តែចូលយ៉ាងណា?*

*អារុណឆ្លើយភ្នាមឥតបង្អង់:*

*ហ៊ឺ! ទៅឆោតអី ដើរចូលត្រង់ៗ រួចទៅគោះទ្វារហៅវាមកបានហើយ! យើងមានដាវគ្រប់ដៃ។ កាលណាវាបើកទ្វារចេញមកយើងកៀកកវា ចង់វាដូចជាវាចងបងកាលឯង កាលជាប់គុកដូច្នោះ!*

*មហាកាលសើចនឹងអនុស្សាវរីយ៍ ដែលអារុណរំលឹកក្នុងពេលជិតមានអាសន្ននេះ។*

*នាយឡំសួរថា:*

*ចូលតាមណាលោកគ្រូ?*

*មហាកាលឆ្លើយ:*

*ដើរព័ទ្ធមួយជុំផ្ទះសិន ក្រែងមានឆ្កែ។*

*ជនទាំងប្រាំក៏ដើរមួយជុំផ្ទះយ៉ាងអង់អាច បីដូចឥតមានរឿងអ្វីឡើយ។*

*ឯអារុណវិញ ឥតធ្វើតាមអ្នកឯទៀតឡើយ។ អារុណលោតចុះតាមបង្អួចរួចហួចឮរើតៗ រីឯអ្នកទាំងបួនទៀតក៏រត់ស្រចូលតាមអារុណឥតបង្អង់។*

*ជនទាំងប្រាំបានទៅដល់ផ្ទះ។ ចង្កៀងមួយឆេះផ្ទុងៗ។ នៅសងខាងគ្រែដែលនិលពេជ្រដេក ឃើញមានតុ និងទូរត្រៀបត្រា។*

*អារុណបិទបង្អួចដោយខ្សឹបថា:*

ក្រែងវារត់តាមបង្អួចនេះរួច គិតតែខ្ទប់វាដូចយើងខ្ទប់ដូច្នោះឯង។

មហាកាលលាន់មាត់ថា:

យី! ផ្ទះនេះចំណាប់ចំនួនមែន! ប្រយ័ត្ន!

ជនទាំងប្រាំហូតដាវរឹបដំណាលគ្នា។ នាយឡំ និងនាយកត គេចទៅខាងឆ្វេងមានមាត់ទ្វារ ត្រៀមចាំលោតទៅចាប់និលពេជ្រកាលណានិលពេជ្រមកដល់មាត់ទ្វារនេះ។ វីរៈអែបខ្លួននឹងជញ្ជាំងខាងស្ដាំមាត់ទ្វារ។ មហាកាលនឹងអារុណ ក្រោយពីពេលចោលកន្ទុយភ្នែកយ៉ាងលឿនទៅលើវត្ថុនានាដែលនៅក្នុងផ្ទះ ហើយក៏ចូលស្ទុងទៅរកចំណីដោយវាត់ដាវម៉ាំងលើគូថនិលពេជ្រដែលកំពុងដេកលក់។ អារុណស្រែកឡើងថា:

អ្ហ៎! លោកសម្លាញ់ចាស់! ក្រោកឡើងឆាប់ៗ។

និលពេជ្រជូតភ្នែកល្វីល្វើ ស្រាប់តែភ្ញាក់ដូចគេកន្ត្រាក់ ព្រោះឃើញមហាកាល។ រហ័សដូចខ្លា និលពេជ្រគេចខ្លួនផាំងចម្ងាយពីរម៉ែត្រ ដកដាវរឹត!

ហាសៗ បងកាលអ្នកណាមិនស្គាល់និលពេជ្រ។

អារុណក្វែតកាប់និលពេជ្រម៉ាំង ផូងៗ ជាប់ញាប់ដូចកង្ហារ។ និលពេជ្រកាត់ប៉ាំង យ៉ាងញាប់ដៃ។ ផូងទៅផូងមកៗ ញាប់ៗ ល្អមើលជាទីអស្ចារ្យ។

មហាកាលឈរមើល ញញឹមយ៉ាងស្រស់ រួចក៏ស្ទុះទៅច្រានអារុណចេញ ចូលកាប់និលពេជ្រប៉ាច់ៗ។ និលពេជ្ររងគេចរត់ថយ មហាកាលវាយរន្ទើនរណ្ដំគ្នា សួរយ៉ាងពិរោះដោយនិយាយថា:

អញចង់យូរហើយ ! អញនឹកមិនភ្លេចទេ កាលអញជាប់គុក! ហ៊ឺស! អញហុតឈាមអាឲ្យបានក្នុងពេលនេះ។

មហាកាលវាត់រឹងចំកនិលពេជ្រ ស្រាប់តែមានដាវមួយទៀតមករងចែសទាន់។ និលពេញលេបទឹកមាត់ក្អឿកៗ។ មហាកាលខឹងយ៉ាងខ្លាំងស្ទុះរឹងទៅរកមនុស្សថ្មីនេះ។ អារុណស្ទុះរឹងចូលទៅទៀត។

វីរៈ នាយកត នាយឡំ ក៏ឥតនៅព្រងើយស្ទុះរឹងទៅដែរ ដាវនៅដៃ។ បុរសថ្មីកាត់ដាវជាប់ទាំងប្រាំយ៉ាងខែង ហាក់ដូចគ្មានប្រឹងអ្វីដល់តិចតួចសោះ។

អារុណដោយខឹងខ្លាំងពេក ចាក់គេមិនត្រូវស្រែកថា:

អត្ថបទដោយ៖ មាស សុភាព

អាណា?

ហ៊ឹសៗៗ

អារុណលុតជង្គង់គ្រឹប:

លោកគ្រូ! លោកគ្រូ!

ជនទាំងប្រាំឈប់ដូចម៉ាស៊ីន ស្ទុះទៅឱបបុរសថ្មីនេះ ឥតបង្អង់ឡើយ។ និលពេជ្រដែលឈរមើលគេជួបគ្នា ភ័យរឹតតែខ្លាំងឡើង គិតរត់តែមានន្ទចោលកន្ទុយភ្នែកទាន់ យកដាវរាំងទ្វារជាប់ ធ្វើឲ្យនិលពេជ្រឈរស្ងៀមមួយកន្ទែង។

មហាកាលសួរថា:

លោកគ្រូអញ្ជើញទៅណាបាត់យូរម្ល៉េះ?

ខ្ញុំឥតទៅណាទេ!

លោកគ្រូសុខសប្បាយជាទេ?

ជាធម្មតា។

អារុណនិយាយប្រដែងថា:

លោកគ្រូអើយ! ពួកយើងចាំមើលតែផ្លូវលោកគ្រូៗ ដល់បាត់យូរពេក ទើបពួកយើងមកតាមនេះឯង។

មានន្ទ ទះស្មាអារុណសើច រួចប្រាប់ជនទាំងប្រាំឲ្យមករួមគ្នាខ្សឹបថា

ទៅសិនចុះ! ភ្លាមទៅស្កាត់ផ្លូវភ្នំស្វាយ។ ព្រឹកនេះជិតភ្លឺបក្សីវាំងនាំមាសពេជ្រទៅដាក់ក្នុងរូងភ្នំស្វាយ។

អ្នកទាំងអស់បើកភ្នែកធំៗ។ មានន្ទបន្តទៅទៀតថា:

គឺមាសពេជ្ររបស់ឪពុកខ្ញុំ បក្សីវាលួចប្លន់ជប់ថ្ងៃមុននេះឯង។ គ្នាវាម្តែនាក់។ វាយយកឲ្យបាន។ យើងបាន មាសពេជ្រនេះ យើងយកទៅធ្វើសឹកសង្គ្រាមយើងទៀត! ប្រយ័ត្ន! កុំអោយអ្នកណាដឹងឲ្យសោះណា! ទៅៗ! កុំនៅយូរ។

**(សូមរង់ចាំតាមដានភាគទី៦៦ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព